# របាយការណ៍

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករា

## និងទិសដៅការងារបន្ត ខែកុម្ភៈ ឆ្នាំ២០២១

នាព្រឹកថ្ងៃសៅរ៍ ៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១

**ទីកន្លែង** : ស្នាក់ការគណបក្សស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

**សមាសភាពចូលរួម** : ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន អនុប្រធានក្រុមការងារថ្នាក់កណ្តាល និងថ្នាក់ខេត្ត អ្នកតំណាងរាស្ត្រ មណ្ឌលកំពង់ស្ពឺ អភិបាលស្រុក ការិយាល័យជំនាញជុំវិញស្រុកបរសេដ្ឋ តំណាងមន្ទីរ គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សា សមាជិកគណៈកម្មាធិការបក្សឃុំ និងមន្ត្រីស្នាក់ការគណបក្សស្រុក សរុបចំនួន ៦១ រូប (ស្ត្រី៤រូប)។

**គណៈអធិបតី** : ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ឯកឧត្តម **សត្យា ឌុច** និងឯកឧត្តម **ហេង សុខគង់**

**ក្រោមអធិបតីភាព** : ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានក្រុមការងារគណបក្សចុះជួយស្រុកបរសេដ្ឋ។

១.មតិបើក: ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** មានមតិស្វាគមន៍ និងបើកកិច្ចប្រជុំ និងបានជម្រាបជូនពី របៀបវារៈនៃកិច្ចប្រជុំ ព្រមទាំងបញ្ហាផ្សេងៗ។ បន្ទាប់មក ឯកឧត្តមប្រធាន បានអនុញ្ញាតជូន **លោក ឈឺន សុធន** ប្រធានគណបក្សស្រុកបរសេដ្ឋ អានរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែមករា និងទិសដៅការងារបន្ត ខែកុម្ភៈ ឆ្នាំ២០២១។

២. របាយការណ៍ :

**២.១- សភាពការណ៍ទូទៅ ៖**

ក) ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដូចជា បទល្មើសព្រហ្មទណ្ឌមាន៣លើក កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសបាន៣ករណី ការបង្ក្រាបបទល្មើសគ្រឿងញៀនបាន៣ករណី ការងារសណ្តាប់ធ្នាប់សាធារណៈ ការងារចរាចរណ៍ ការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី និងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

ខ) ការងារកសិកម្ម : ស្ថានភាពប្រមូលផលស្រូវរដូវវស្សា មានស្រូវស្រាល ស្រូវកណ្តាល ស្រូវធ្ងន់និងដំណាំរួមផ្សំជាច្រើនមុខ ព្រមទាំងការងារចិញ្ចឹមសត្វផងដែរ។

គ) សកម្មភាពគណបក្សនយោបាយ ដូចជា ការងារនយោបាយសតិអារម្មណ៍ ការងារចិញ្ចឹមចលនា ពង្រឹងអង្គការចាត់តាំងគណបក្ស និងពង្រឹងសមាជិកបក្ស។

ឃ) សកម្មភាពក្រុមការងារថ្នាក់កណ្តាល និងថ្នាក់ខេត្តចុះជួយឃុំទាំង១៥។

ង) ការងារយុវជនគណបក្ស : បានរៀបចំរចនាសម្ព័ន្ធ តួនាទី និងរបៀបរបបធ្វើការងារ។

ច) ផ្សព្វផ្សាយពីវិធានការ ការបង្ការ ការចម្លងជំងឺកូវីដ-១៩។

## ២.២- ទិសដៅការងារបន្ត សម្រាប់ខែកុម្ភៈ

ក) រក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឱ្យបានរឹងមាំ។

ខ) ផ្តល់សេវាសាធារណៈជូនប្រជាជនឱ្យបានកាន់តែប្រសើរ។

គ) មណ្ឌលសុខភាពទាំង១៣ ត្រូវផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ ជាពិសេសតាមផ្ទះដែលមានសមាជិកវិលត្រឡប់ពីខាងក្រៅប្រទេស ត្រូវធ្វើចត្តាឡីស័កតាមការណែនាំរបស់ក្រសួងសុខាភិបាល។

ឃ) បន្តចុះរៀបចំបញ្ជីឈ្មោះសមាជិកគណបក្សតាមមូលដ្ឋានតាមគោលការណែនាំរបស់បក្ស។

ជាកិច្ចបន្ត ឯកឧត្តមប្រធាន បានអនុញ្ញាតជូន ឯកឧត្តម **សត្យា ឌុច** អ្នកតំណាងរាស្ត្រ មណ្ឌលកំពង់ស្ពឺ មានមតិណែនាំអំពីការងារបក្ស ៖

- អ្វីដែលយើងចង់បាន គឺការឈ្នះឆ្នោត ដើម្បីកាន់អំណាចយូរអង្វែង។
- ឯកភាពខាងទស្សនៈ « ប្រៀបធៀបខេត្តនឹងស្រុក ខេត្តជាថ្នាក់យុទ្ធសាស្ត្រ ស្រុកថ្នាក់យុទ្ធវិធី »
- សារៈសំខាន់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ឆ្នាំ២០២២ ដើម្បីបោះឆ្នោតបាន វាទាក់ទងទៅនឹងកត្តាទី១) ត្រូវថតចម្លងបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០២១ ចែកជូនដល់សមាជិកបក្ស ទី២) ណែនាំពួកគាត់ឱ្យទៅមើលឈ្មោះ។ ដើម្បីធ្វើការបោះឆ្នោតបាន ត្រូវធ្វើ សន្និបាតគណបក្សឃុំ តាមនីតិវិធី៣ គឺទី១) របាយការណ៍តំណាងរាស្ត្រស្តីពីគោលការនយោបាយ ២០១៧ ដល់ ២០២២ ទី២) គោលការណ៍នយោបាយគណបក្សពីឆ្នាំ២០២២ ដល់ ឆ្នាំ២០២៧ ទី៣) បញ្ជីឈ្មោះសមាជិករបស់គណបក្សប្រជាជន ដើម្បីដាក់ជាបេក្ខជន។ ធ្វើបច្ចុប្បន្នភាពសមាជិកបក្សដោយស្រង់ឈ្មោះសមាជិកបក្សចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ។
- សម្រាប់ការបោះឆ្នោត « បុច្ចុប្បន្ន NEC យកភូមិជាការិយាល័យបោះឆ្នោត ដូច្នេះការពង្រឹងភូមិជាអាទិភាព ក្រុមការងារគួរថតចម្លងបញ្ជីបោះឆ្នោតចែកជូនភូមិដើម្បីផ្ទៀងផ្ទាត់ ស្រុកត្រូវមានផែនការសន្ទស្សន៍ដល់ឃុំ ...., ដោះស្រាយភូមិដែលអសកម្ម .....។
- ត្រូវមានការឯកភាពគ្នាលើទស្សនៈ ពង្រឹងរចនាសម្ព័ន្ធភូមិតាមរយៈការត្រួតពិនិត្យក្បាលម៉ាស៊ីនដឹកនាំគណៈអចិន្ត្រៃយ៍ឃុំ ត្រូវដោះស្រាយរាល់បញ្ហានានា បើសិនជាភូមិគ្មានសមត្ថភាព ភូមិគ្មានសុវត្ថិភាព ត្រូវចាំថា ទី១) ដោះស្រាយក្បាលម៉ាស៊ីនដឹកនាំ ទី២)ដោះស្រាយសមត្ថភាព ទី៣) ដោះស្រាយកិច្ចសហការ និងការគាំទ្រ។
- បន្តពង្រឹងគ្រប់រចនាសម្ព័ន្ធអង្គការចាត់តាំងគណបក្ស និងអង្គការមហាជនគណបក្សគ្រប់ថ្នាក់ ពង្រឹងមូលដ្ឋានឱ្យចេះធ្វើការងារដោយខ្លួនឯង មានការបំពាក់បំប៉នផ្នែកសតិអារម្មណ៍ ពង្រឹងសមាជិកបក្សថ្មី។ បន្តគ្រប់គ្រងមុខសញ្ញាសំខាន់ៗដែលមានឥទ្ធិពលគ្របដណ្តប់លើការបោះឆ្នោត ដើម្បីពង្រឹងទស្សនៈនយោបាយ សតិអារម្មណ៍ និងការចាត់តាំង។

បន្ទាប់មក ឯកឧត្តម **ហេខ សុខគង់** អនុប្រធានទី១ ក្រុមការងារគណបក្សស្រុកបសេដ្ឋ បានលើកឡើងពី ព័ត៌មានបឋមនៃការបោះឆ្នោតរបស់ឃុំ/សង្កាត់អាណត្តិទី៥ ប្រហែលនឹងធ្វើនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០២២។

- ចាប់ពីពេលនេះតទៅ រហូតដល់ថ្ងៃបោះឆ្នោត យើងបានជួបជុំគ្នាប្រហែលជា១៥ដងទៀតទេ គឺមានរយៈពេលខ្លីណាស់ ដូច្នេះត្រូវរៀបចំផែនការសកម្មភាពឱ្យបានច្បាស់លាស់។
- តើផែនការណាខ្លះជាផែនការអាទិភាព ផែនការយុទ្ធអង្វែង និងផែនការចំណុចសូន្យ។ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ តើនៅក្នុងភូមិ ឃុំ ក៏ដូចជាក្រុមការងារចុះជួយឃុំ មានបញ្ហាដែរឬទេ? បើមាន ត្រូវរាយការណ៍ជូន ឯកឧត្តមប្រធាន និងឯកឧត្តម អ្នកតំណាងរាស្ត្រ ដើម្បីរកដំណោះស្រាយ។
- អ្វីខ្លះជាគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា នៅឆ្នាំ២០១៧ នៅពេលដែលយើងឃោសនាបោះឆ្នោត រហូតមកដល់បច្ចុប្បន្ននេះយើងធ្វើបានអ្វីខ្លះ ធ្វើបានប៉ុន្មានភាគរយ។ ត្រូវរៀបចំឱ្យហើយ តើនៅតាមភូមិនីមួយៗទទួលបានសមិទ្ធផលអ្វីខ្លះ ដាក់ចូលទៅក្នុងគោលនយោបាយបោះឆ្នោតឆ្នាំ ២០២២។
- ត្រូវស្គាល់ខ្លួនឯងឱ្យបានច្បាស់ តើនៅក្នុងគណបក្សឃុំ សមត្ថភាពរបស់មេភូមិ មេឃុំ មានកម្រិតប៉ុន្មាន? បច្ចុប្បន្នគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានលើកស្លាកជាច្រើន ហើយធំៗ គណបក្សនេះនឹងដើរតួនាទីជាគណបក្សប្រឆាំងដ៏ធំ។ គណបក្សនេះមានគ្រូយុទ្ធសាស្ត្រមកពី៣ប្រទេស ដើម្បីរៀបចំគោលនយោបាយឱ្យគណបក្ស គេបង្រៀនពីយុទ្ធវិធីក្នុងការបោះឆ្នោត និងបង្រៀនពីយុទ្ធវិធីប្រឆាំង។ ទាក់ទាញកម្លាំងយុវជនឱ្យបានមុនគេ ដោយចាប់ពីអាយុ១៦ឆ្នាំឡើងទៅ ដល់ឆ្នាំ២០២២-២០២៣ បានគ្រប់អាយុ១៨ឆ្នាំ ដើម្បីចូលរួមការបោះឆ្នោត ហើយត្រូវពង្រឹងបញ្ញាសតិអារម្មណ៍ដល់កម្លាំងក្រុមយុវជននេះ។
- ផែនការសកម្មភាព ខេត្តបានដាក់យុទ្ធសាស្ត្រ ថ្នាក់ស្រុក ថ្នាក់ឃុំ ថ្នាក់ភូមិ គឺជាអ្នកអនុវត្ត ឃុំនីមួយៗត្រូវធ្វើការបត់បែនតាមសកម្មភាព អ្វីដែលសំខាន់គឺក្រុមគោលដៅ មានគ្រូបង្រៀន គ្រូពេទ្យ ព្រះសង្ឃ ។ល។ ត្រូវមានទិន្នន័យឱ្យបានច្បាស់លាស់។
- ត្រៀមរៀបចំហិរញ្ញវត្ថុឱ្យបានរួចរាល់ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការចំណាយឱ្យបានសមស្របតាមផែនការសកម្មភាព។
- ការរៀបចំយុវជន គឺទី១) យុវជនបក្ស ទី២) អង្គការមហាជនដែលគាំទ្រគណបក្សប្រជាជនកម្ពុជា យើងត្រូវកំណត់ឱ្យបានច្បាស់លាស់ពីយុទ្ធសាស្ត្រសំខាន់ៗ ដូចជាការពង្រឹងបញ្ញាសតិអារម្មណ៍ ការគ្រប់គ្រង ការចាត់តាំង និងការអនុវត្ត លើសពីនេះគឺការលើកទឹកចិត្ត។ ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្តីណែនាំ ដើម្បីឱ្យរដ្ឋបាលឃុំ នីមួយៗជ្រើសរើសជំនួយការ បើឃុំតូចផ្តល់ជូន២នាក់ ឃុំធំផ្តល់ជូន៣នាក់។
- យន្តការរៀបចំភូមិ ឃុំ ដើម្បីស្ទាបស្ទង់មតិសម្រាប់បេក្ខភាពក្រុមប្រឹក្សាឃុំ ការបោះឆ្នោតឃុំមានសារៈសំខាន់ណាស់ សម្រាប់ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខេត្ត រដ្ឋសភា និងព្រឹទ្ធសភា។
- សូមពិនិត្យមើលលើបងប្អូនមួយចំនួនដែលមកពីគណបក្សដទៃ តើសតិអារម្មណ៍របស់គាត់យ៉ាងដូចម្តេច? នៅពេលឮថា មេដឹកនាំរបស់គាត់នឹងវិលត្រឡប់ចូលស្រុកវិញ មានការជ្រួលច្របល់ឬទេ? បើគាត់មានសតិអារម្មណ៍មិនហ្នឹងនរទេ សូមរាយការណ៍ជាបន្ទាន់ជូនប្រធានគណបក្សស្រុក ឬឯកឧត្តមប្រធានក្រុមការងារ។
- ឯកឧត្តមប្រធានក្រុមការងារតម្រូវឱ្យមានការរៀបចំបញ្ជីឈ្មោះ ដោយត្រួតពិនិត្យតាមប្រព័ន្ធកុំព្យូទ័រ លោកបានឱ្យជាទម្រង់គំរូមួយ ដែលមានលេខកូដខេត្ត លេខកូដឃុំ លេខកូដការិយាល័យ.., ដើម្បីរៀបចំដាក់ចូលទៅក្នុងប្រព័ន្ធទិន្នន័យតាមតារាង Excel។

៣.ការពិភាក្សា : មានការចូលរួមពីមេឃុំទាំង១៥ បានលើកពីបញ្ហាប្រឈម និងភាពយឺតយ៉ាវនៃការចុះឈ្មោះជាសមាជិកគណបក្ស នៅក្នុងមូលដ្ឋានរបស់ខ្លួនដោយមូលហេតុដូចតទៅ ៖

- មេភូមិមួយចំនួនមានជំងឺរ៉ាំរ៉ៃ ចាស់ជរា អសកម្ម ភាគច្រើនជាស្ត្រី និងចំណេះដឹងនៅមានកម្រិត។
- ការចុះឈ្មោះសមាជិកគណបក្សក្នុងបញ្ជីគ្រប់គ្រង គប.១ គប.២ គប.៣ ទើបបញ្ចប់នៅចុងខែធ្នូ ឆ្នាំ ២០២០។
- ការចុះឈ្មោះសមាជិកគណបក្សក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០២២
- សាមគ្គីភាពផ្ទៃក្នុង ឃុំខ្លះនៅមិនទាន់បានល្អ
- ភូមិមួយចំនួនមានគណបក្សនយោបាយ២ បានចុះឈ្មោះបោះឆ្នោត គឺគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងគណបក្សខ្មែររួបរួមជាតិ

៤.សេចក្តីសម្រេច (ការផ្តល់អនុសាសន៍)៖

- សូមកោតសរសើរចំពោះវឌ្ឍនភាពការងារកន្លងមក ការអនុវត្តភូមិ ឃុំមានសុវត្ថិភាព អាជ្ញាធរគ្រប់គ្រងសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ថែរក្សាស្ថិរភាព ជូនប្រជាជនគ្រប់មូលដ្ឋានបានល្អក្នុងរយៈពេលមានបញ្ហាជំងឺកូវីដ-១៩ ។
- បញ្ហាជំងឺកូវីដ-១៩ វាមិនទាន់វិលត្រឡប់ទៅសភាពដើមវិញទេ វាបានធ្វើឱ្យរាំងស្ទះការងាររបស់យើងមួយចំនួន ក៏ប៉ុន្តែរហូតមកដល់ពេលនេះយើងអាចដំណើរការបានស្ទើតែធម្មតា។ ជំងឺនេះធ្វើឱ្យមានបញ្ហាច្រើនណាស់ ប្រទេសនីមួយៗបានជួបនូវវិបត្តិភាពថវិកា ទទួលរងផលប៉ះពាល់សេដ្ឋកិច្ច និងសុខមាលភាពសាធារណៈ ថែមទាំងបានគំរាមកំហែងដល់ការអភិវឌ្ឍសង្គមយ៉ាងធ្ងន់ធ្ងរ។ រាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់នូវកញ្ចប់វិធានការ ដើម្បីរក្សាលំនឹងសកម្មភាពអាជីវកម្មដែលរងផលប៉ះពាល់ ជួយសម្រាលដល់ជីវភាពកម្មករ និយោជិត និងប្រជាពលរដ្ឋកម្ពុជាផងដែរ។ យើងត្រូវតែរក្សានូវវិធានការការពារការចម្លងជំងឺកូវីដ-១៩នេះ ត្រូវបន្តការប្រុងប្រយ័ត្នដោយរក្សាអនាម័យ ដូចជា ពាក់ម៉ាស់ លាងដៃនឹងសាប៊ូ ឬអាល់កុល ចេះរស់នៅដោយមានគម្លាតសុវត្ថិភាពចំងាយ១.៥ ម ពីគ្នា និងណែនាំឱ្យធ្វើចត្តាឡីស័កចំពោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស។ ប្រទេសមួយចំនួនបានចាប់ផ្តើមចាក់វ៉ាក់សាំងរួចហើយ ហើយប្រទេសកម្ពុជាក៏ត្រៀមលក្ខណៈចាក់វ៉ាក់សាំងនេះផងដែរសម្រាប់មន្ត្រីរាជការ និងប្រជាពលរដ្ឋដែលមានចំនួន១លានដូស ជាអំណោយដ៏ថ្លៃថ្លារបស់ប្រទេសចិន។ រាជរដ្ឋាភិបាលបានបន្តទំនុកបម្រុងដល់ជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះតាមកម្មវិធីឧបត្ថម្ភសាច់ប្រាក់។ ជំងឺកូវីដ-១៩ នៅតែបន្តជះឥទ្ធិពលដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដែលជាបន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់រាជរដ្ឋាភិបាល ហើយមិនទាន់អាចកំណត់បានថា តើនឹងបញ្ចប់នៅពេលណា។
- កំណត់យកការប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែដោយយកសប្តាហ៍ទី៣នៃខែនីមួយៗ (ចន្លោះពីថ្ងៃទី១៦-២០)
- ធ្វើបច្ចុប្បន្នភាពនៃសមាជិកគណបក្ស ដែលបានចុះឈ្មោះបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ នៅឆ្នាំ២០២២ ដោយត្រួតពិនិត្យ ផ្ទៀងផ្ទាត់នឹងបញ្ជីបោះឆ្នោតរបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ឆ្នាំ២០២០។

- ត្រូវលើកកម្ពស់ស្មារតីសាមគ្គីឯកភាពជាតិ ស្ថិរភាពភាពនយោបាយ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។
- បន្តអប់រំប្រជាជនឱ្យបានយល់ដឹងពីវិធានការអនុវត្តច្បាប់ ចំពោះជនដែលប្រព្រឹត្តិបទល្មើស ពង្រឹងការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធមនុស្សក្នុងក្របខណ្ឌនៃគោលការណ៍នីតិរដ្ឋ។ ធ្វើការវាយបកទៅលើពួកប្រឆាំងផ្កាប់មុខ ពួកឧទ្ទាមក្រៅច្បាប់ ចំពោះការផ្សព្វផ្សាយនៃការវិលត្រឡប់របស់មេឧទ្ទាម។
- ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្តីណែនាំ ដើម្បីឱ្យរដ្ឋបាលឃុំនីមួយៗ អាចជ្រើសរើសជំនួយការរដ្ឋបាលឃុំប្រកបដោយតម្លាភាព និងគណនេយ្យភាព ក្នុងការជួយបម្រើការងារតាមតម្រូវការជាក់ស្តែង។ រដ្ឋបាលឃុំ ដែលមានក្រុមប្រឹក្សាចំនួន៥រូប ដល់០៧រូប អាចជ្រើសរើសជំនួយការចំនួន២រូប និងរដ្ឋបាលឃុំ ដែលមានក្រុមប្រឹក្សាចំនួន០៩រូប ដល់១១រូប អាចជ្រើសរើសជំនួយការចំនួន៣រូប។
- ចំពោះបញ្ហាមេរោគអេដស៍ បើសិនជាមាននរណាម្នាក់ក្នុងភូមិ មានផ្ទុកមេរោគអេដស៍ សូមទៅទទួលសេវាសុខាភិបាលសាធារណៈ និងលេបថ្នាំឱ្យបានទៀងទាត់ តាមការណែនាំរបស់គ្រូពេទ្យ។ តើថ្នាក់ស្រុក ថ្នាក់ឃុំ បានរៀបចំបង្កើតគណៈកម្មាធិការអេដស៍ហើយឬនៅ បានដំណើរការហើយឬនៅ បានរៀបចំគម្រោងផែនការហើយឬនៅ?។ ចំពោះថ្នាក់ឃុំមានការងាយស្រួលក្នុងការរៀបចំបញ្ចូលជាសមាសភាពគណៈកម្មាធិការអេដស៍ ដោយយកគណៈកម្មាធិការកិច្ចការនារី និងកុមារ អង្គការសង្គមស៊ីវិល និងអ្នកដែលមានឥទ្ធិពលក្នុងសង្គម។ សូមអភិបាលស្រុក ដឹកនាំការងារ និងបញ្ជ្រាបសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ចូលទៅក្នុងផែនការអភិវឌ្ឍន៍ ឃុំ/សង្កាត់ ដោយប្រើថវិកាសេវាសង្គម។
- ចំពោះបញ្ហាគ្រឿងញៀន សូមអាណាព្យាបាលត្រូវអប់រំណែនាំកូនចៅក្នុងគ្រួសារឱ្យជៀសឆ្ងាយពីគ្រឿងញៀន។ គ្រឿងញៀនបំផ្លាញគ្រួសារឱ្យវិនាស ដូច្នេះត្រូវទប់ស្កាត់នៅតាមសាលា កុំឱ្យគ្រឿងញៀនចូលបាន។

## ៥.មតិបិទ

ឯកឧត្តមប្រធាន បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តម អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ ឯកឧត្តម អនុប្រធានទី១ ក្រុមការងារគណបក្សស្រុកបសេដ្ឋ និងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានក្រុមការងារ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួម។

សូមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ និងប្រកាសបិទ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:២៥នាទីប្រកបដោយបរិយាកាសរីករាយនិងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃសៅរ៍ ៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១

អ្នកធ្វើកំណត់ហេតុ

ស៊ុត_ថនផាន់

បានឃើញ និងឯកភាព

ប្រធាន ក្រុមការងារចុះជួយស្រុកបសេដ្ឋ

អៀង_មូលី